Cambodian - Pediculosis (Head Lice)

ការកើតមានជាហ្វូង



# ជម្ងឺចៃ (ចៃក្បាល)

## ចំណុចសំខាន់ៗ

- ភាគច្រើនចៃក្បាលកើតមានជាទូទៅ នៅក្នុងចំណោមក្មេងសាលា។ វាមិនសូវកើតមាននៅក្នុងចំណោមទារកទេ
- គេមិនអាចមើលឃើញចៃដោយស្រួលឡើយ ក៏ប៉ុន្តែគេអាចមើលឃើញពងចៃនៅជាប់ស្និតនឹងសក់ ។
- ត្រូវប្រើថ្នាំកក់សក់ ឬទឹកសាប៊ូកក់សក់ដើម្បីកំចាត់ចៃ ហើយត្រូវប្រើស្របទៅតាមការណែនាំ មួយអាទិត្យក្រោយមកត្រូវកក់ម្តងទៀត
- ប្រើសាប៊ូកក់សក់ឲ្យទន់ ដើម្បីជួយឲ្យងាយស្រួលក្នុងការសិតយកពងចៃ និងចៃជាមួយស្និត
- ប្រើសាប៊ូកក់សក់ឲ្យទន់ និងស្និត រហូតទាល់តែលែងឃើញមានពងចៃនៅលើសក់ក្បាល
- គ្រប់ទាំងសមាជិកគ្រួសារដែលមានចៃ ត្រូវតែព្យាបាលដើម្បីកុំឲ្យឆ្លងនៅក្នុងគ្រួសារទៀត
- មិនត្រូវប្រើក្រាសសិតសក់ ច្រាសត្រដុសសក់ មួក និងគ្រឿងពាក់ក្បាលរួមគ្នាឡើយ

## តើវាជាអ្វី?

ចៃក្បាលគឺជាសត្វល្អិតគ្មានស្លាប ដែលបណ្តាលឲ្យមានការរមាស់ស្បែកលលាដ៏ក្បាល។ វាចិញ្ចឹមជីវិតដោយសារឈាមមនុស្ស ហើយច្រើនរស់នៅ ហើយពងដាក់សក់ផ្នែកខាងក្រោយក្បាល និងក និងខាងក្រោយត្រចៀក។ មនុស្សភាគច្រើនត្រឡប់ជាមានប្រតិកម្មទៅនឹងចៃ និងពងវា ហើយបណ្តាលឲ្យរមាស់។ ការអេះអាចបណ្តាលឲ្យរលាកស្បែក (ក្រហម ស្វាយ ឬសម្បុរត្នោត) ដែលមានចេញទឹក និងក្រមរ។

មិនមែនមនុស្សគ្រប់ៗគ្នាសុទ្ធតែមានប្រតិកម្មទៅនឹងចៃទេ ហើយមនុស្សទាំងនេះអាចមានចៃក្បាល ក៏ប៉ុន្តែឥតរមាស់ ឬឥតបង្ហាញសញ្ញាប្រាប់អ្នកដទៃអំពីវត្តមាននៃការមានចៃក្បាលទេ។

ចៃក្បាលកើតមានជាទូទៅនៅក្នុងចំណោមក្មេងចូលសាលារៀន មត្តេយ្យសាលា ឬកន្លែងមើលថែរក្សាក្មេង។ វាកម្រកើតមាននៅក្នុងចំណោមទារកណាស់។ កុមារទាំងនេះត្រូវបានឆែកពិនិត្យមើល ដោយសារការរកឃើញចៃក្បាល ឬពងរបស់វាជាប់ស្និតទៅនឹងសក់ គឺនៅក្បែរស្បែកលលាដ៏ក្បាល។ មិនដូចអង្គែក្បាលទេ គេពុំអាចសិតយកពងចៃជាមួយក្រាសធម្មតាឡើយ។

ចៃរស់នៅលើលលាដ៏ក្បាល ហើយពងដាក់សក់។ ចៃមានទំហំប្រហែលស្មើនឹងក្បាលម្ជុល ហើយមនុស្សភាគច្រើនមានចៃចំនួនតែ៨-១០ប៉ុណ្ណោះនៅលើលលាដ៏ក្បាលរបស់គេ ដូច្នេះប្រហែលជាការពិបាកនឹងមើលឃើញវាណាស់។ ផ្ទុយទៅវិញ មានពងចៃប្រហែលជារាប់រយជាប់ស្និតទៅនឹងសក់ ដែលគេអាចមើលឃើញវាយ៉ាងងាយស្រួល។ ការប៉ះក្បាលគ្នា ឬប្រើមួកដូចគ្នា ការប្រើគ្រឿងពាក់ក្បាល ឬក្រាសសិតសក់រួមគ្នា នាំឲ្យឆ្លងចៃពីម្នាក់ ទៅម្នាក់ទៀត។ ចៃមិនអាចរស់នៅឆ្ងាយពីខ្លួនមនុស្សលើសពីរ ឬបីនាទីឡើយ។

## វាគេការពារវាដោយរបៀបណា?

គ្រប់ទាំងសមាជិកគ្រួសារដែលមានចៃ ត្រូវតែព្យាបាលដើម្បីការពារកុំឲ្យឆ្លងនៅក្នុងគ្រួសារទៀត។ គេមិនត្រូវប្រើក្រាសសិតសក់ ច្រាសត្រដុសសក់ ឬគ្រឿងពាក់ក្បាលរួមគ្នាទេ។ ត្រូវលាងសំអាតច្រាសត្រដុសសក់ និងក្រាសសិតសក់ជាមួយទឹកយ៉ាងក្តៅ ហើយសម្ងួតវាដោយយកចិត្តទុកដាក់។

## តើគេអាចព្យាបាលវាដោយរបៀបណា?

ត្រូវប្រើថ្នាំកក់កំចាត់ចៃក្បាល ពេលណាលោកអ្នកមើលឃើញចៃ ឬពងចៃនៅសក់របស់កូនក្មេង។ ដើម្បីឆែកមើលចៃក្បាល លោកអ្នកអាចប្រើសាប៊ូកក់សក់ឲ្យទន់ធម្មតា និងស្និត នេះគឺជារបៀបដែលអាចប្រើសំរាប់កំចាត់ចៃក្បាល។

ដើម្បីកំចាត់ចៃដោយប្រើតាមរបៀបនេះ ត្រូវប្រើស្និតសិតសាប៊ូកក់សក់ឲ្យទន់ ចេញពីសក់ស្ងួត ដោយចាប់ពីលលាដ៏ក្បាល ចុះទៅចុងសក់។ វែកសក់ជាស្រទាប់ៗ ជូតសាប៊ូកក់សក់ឲ្យទន់ដាក់ទៅលើក្រដាសជូតមាត់ ដើម្បីច្បូតយកពង និងចៃចេញ។ ត្រូវសិតស្រទាប់សក់នីមួយៗឲ្យបានយ៉ាងហោចណាស់ចំនួនប្រាំដង។ កាលណាលែងឃើញមានចៃ ឬពងនៅលើស្និតសិតសក់ ត្រូវលាងជំរះក្បាលទាំងមូលជាមួយទឹកក្តៅឧណ្ហៗ។ បញ្ហានេះអាចកើតមានឡើងជាថ្មីទៀត ប្រសិនបើឃើញមានពងរស់នៅសល់ក្នុងសក់។ ត្រូវឆែកមើលសក់កុមារតាមរបៀបនេះឲ្យបានរៀងរាល់អាទិត្យ។

មានថ្នាំកក់ ឬសាប៊ូកំចាត់ចៃក្បាលមួយចំនួន ដែលអាចរកបានពីឱសថស្ថាន។ មិនមែនគ្រប់អស់ទាំងថ្នាំកំចាត់ចៃក្បាល ល្អសមរម្យសំរាប់កូនក្មេង និងស្ត្រីមានផ្ទៃពោះទេ ដូច្នេះសូមឆែកមើលឲ្យបានហ្មត់ចត់ជាមួយឱសថការី។ ថ្នាំទាំងនេះអាចមានប្រសិទ្ធិភាព ប្រសិនបើប្រើស្របទៅតាមការ

**Cambodian - Pediculosis (Head Lice)**

ណែនាំ។ តាមធម្មតាដើម្បីកំចាត់ចៃ និងពងចេញពីសក់ គេត្រូវការប្រើថ្នាំចំនួនពីរលើក ដែលមានចំនួន៧ថ្ងៃឃ្លាតពីគ្នា។

ក្បាលអាចនៅរមាស់អស់រយៈពេលមួយអាទិត្យ ក្រោយពីបានកំចាត់ចៃចេញអស់ហើយ។ ការអេះអាចបណ្តាលឲ្យស្បែកវាក្លាយ ដោយមានចេញទឹក ហើម និងគ្រុនបន្តិចបន្តួច។ ប្រសិនបើការនេះកើតមានឡើង សូមអញ្ជើញទៅជួបវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក។

នេះគឺជាការសំខាន់ដែលត្រូវឆែកមើលកូនក្មេងឲ្យបានរៀងរាល់អាទិត្យ ដោយប្រើរបៀប "Conditioner and Comb' (របៀបកំចាត់ចៃដោយប្រើសាប៊ូកក់សក់ឲ្យទន់ និងស្និត) ឲ្យបានពីរ ឬបីអាទិត្យ បន្ទាប់ពីបានប្រើថ្នាំសម្លាប់សត្វល្អិត ដើម្បីធ្វើឲ្យប្រាកដទៅលើប្រសិទ្ធិភាពនៃការព្យាបាល។

## ពត៌មានបន្ថែមទៀត

- គិលានុបដ្ឋាយិកាមើលថែទាំសុខភាពមាតា និងកុមារ
- ឱសថការីរបស់លោកអ្នក
- វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក
- វេជ្ជបណ្ឌិតឯកទេសជម្ងឺសើរស្បែក

© 2002, Department of Dermatology, St. Vincent’s Hospital Melbourne, Victoria Parade, Fitzroy, Victoria 3065 Australia.